**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ១៧១១៧.២៥.នក.ឥស៣

# សេចក្តីជូនដំណឹង

ក្រសួងរ៉ែនិងថាមពល មានកិត្តិយសសូមជូនដំណឹងដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់សកម្មភាពនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ដែលមានបំណងស្នើសុំលិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ឱ្យបានជ្រាបថា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្មស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ ក្រសួងរ៉ែនិងថាមពល នឹងចាប់ផ្តើមអនុវត្តការស្នើសុំផ្តល់លិខិតអនុញ្ញាតឱ្យនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាតតាមប្រព័ន្ធបញ្ជរតែមួយជាតិ ក្នុងទម្រង់អេឡិចត្រូនិក ស្របតាមសេចក្តីណែនាំស្តីពីនីតិវិធីនៃកិច្ចដំណើរការក្នុងការអនុញ្ញាតឱ្យនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត។

សេចក្តីដូចបានជម្រាបជូនខាងលើ និងអនុលោមតាមបញ្ញត្តិនៃអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ ស្តីពីប្រព័ន្ធបញ្ជរតែមួយជាតិ និងប្រកាសលេខ៥៧៥ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ របស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ ស្តីពីការដាក់ឱ្យអនុវត្តជំហានដំបូងប្រព័ន្ធបញ្ជរតែមួយជាតិ នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់សកម្មភាពនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត អាចដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ស្របតាមខ្លឹមសារនៃសេចក្តីណែនាំរបស់ក្រសួងរ៉ែនិងថាមពលខាងលើ ក្នុងទម្រង់អេឡិចត្រូនិក (Online) តាមរយៈតំណភ្ជាប់ https://live.nsw.gov.kh ឬចូលទៅកាន់គេហទំព័រផ្ទាល់របស់ប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ជាពិសេសធុរជនពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព។

ថ្ងៃពុធ ១២កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៥

ជ. **រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ស៊ុយ ឌីម៉ង់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ១៣១៧២.ឧម៉.នក.ឥថាន

# សេចក្តីណែនាំ
# ស្តីពី
# នីតិវិធីនៃកិច្ចដំណើរការក្នុងការអនុញ្ញាតឱ្យនាំចូលប្រេងកាតនិង/ឬ ផលិតផលប្រេងកាត តាមប្រព័ន្ធបញ្ជរតែមួយជាតិ

យោងអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ ស្តីពីប្រព័ន្ធបញ្ជរតែមួយជាតិ និងអនុលោមតាមបញ្ញត្តិនៃប្រកាសលេខ៥៧៥ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ របស់គណៈ-កម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ ស្តីពីការដាក់ឱ្យអនុវត្តជំហានដំបូងប្រព័ន្ធបញ្ជរតែមួយជាតិ ក្រសួងរ៉ែ និងថាមពលកំណត់នូវនីតិវិធីនៃកិច្ចដំណើរការក្នុងការអនុញ្ញាតឱ្យនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ដោយផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត តាមប្រព័ន្ធបញ្ជរតែមួយជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម។ ការស្នើសុំផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត តាមប្រព័ន្ធបញ្ជរតែមួយជាតិត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

## ១- ការចុះឈ្មោះក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ (Trader)

អ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ដែលទទួលបានអាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់សកម្មភាពនាំចូលនិងគោលការណ៍ឯកភាពលើផែនការនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាតប្រចាំឆ្នាំពីក្រសួងរ៉ែនិងថាមពលរួចហើយ អាចស្នើសុំផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ដោយត្រូវបំពេញបែបបទដូចខាងក្រោម៖

- ចុះឈ្មោះសុំបង្កើតគណនីចូលប្រើប្រាស់ប្រព័ន្ធ តាមរយៈគេហទំព័រ www.nsw.gov.kh ដោយភ្ជាប់នូវឯកសារពាក់ព័ន្ធ មានជាអាទិ៍៖
  - វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប)
  - វិញ្ញាបនបត្របង់ពន្ធប៉ាតង់
  - អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនមានសុពលភាព
  - ឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិក។
- ក្រោយពីបានចុះឈ្មោះរួចហើយ ម្ចាស់គណនីត្រូវចូលប្រើប្រាស់ប្រព័ន្ធ តាមរយៈកូដសម្ងាត់ដែលទទួលបានពីប្រព័ន្ធ និងត្រូវរក្សាទុកឱ្យមានសុវត្ថិភាព ដើម្បីប្រើប្រាស់ប្រកបដោយស្មារតីទទួលខុសត្រូវ។



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

## ២- ការស្នើសុំលិខិតអនុញ្ញាតការនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត

អ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ដែលមានបំណងស្នើសុំលិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាតមួយលើកៗ ត្រូវចូលក្នុងគណនីដែលបានបង្កើតរួចដើម្បីបំពេញទិន្នន័យក្នុងប្រអប់ព័ត៌មាននៃប្រព័ន្ធបញ្ជរតែមួយជាតិ តាមរយៈគេហទំព័រ www.nsw.gov.kh និងភ្ជាប់នូវឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិកដូចខាងក្រោម៖

- ឯកសារពាក់ព័ន្ធនឹងទីតាំងសន្និធិប្រេងកាតនិង/ឬផលិតផលប្រេងកាត
- ឯកសារបញ្ជាក់ពីបរិមាណសន្និធិជាក់ស្តែងតាមប្រភេទនីមួយៗ
- វិក្កយបត្របណ្តោះអាសន្ន ឬវិក្កយបត្រពាណិជ្ជកម្ម
- ឯកសារបញ្ជាក់ពីយថាប្រភេទគុណភាពប្រេង ឬផលិតផលប្រេងកាត
- ផ្ទៀងផ្ទាត់ឡើងវិញនូវភាពគ្រប់គ្រាន់ និងត្រឹមត្រូវនូវរាល់ទិន្នន័យដែលបានបំពេញរួច មុននឹងដាក់ស្នើសុំ (Submit) លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត
- តាមដានព័ត៌មាននៃការឆ្លើយតប ការស្នើសុំកែតម្រូវ និង/ឬភ្ជាប់ឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិកបន្ថែម តាមការតម្រូវរបស់មន្ត្រីជំនាញនៃក្រសួងរ៉ែនិងថាមពល ដែលមានសមត្ថកិច្ច។ ក្នុងករណីចាំបាច់ អគ្គនាយកដ្ឋានប្រេងកាត អាចតម្រូវឱ្យអ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ដាក់ឯកសារគាំទ្រនានាជាឯកសាររឹង (Hard Copy) ជូនក្រសួងរ៉ែនិងថាមពល។

ក្នុងករណីប្រព័ន្ធដំណើរការពុំទាន់បានរលូនឬពេញលេញ អ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាតអាច៖

- យកឯកសាររឹង (Hard Copy) មកដាក់ស្នើសុំនៅក្រសួងរ៉ែនិងថាមពល និង
- យកលិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ដែលចេញដោយក្រសួងរ៉ែនិងថាមពល ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិជំហានដំបូង។

## ៣- ការផ្ទៀងផ្ទាត់សំណើសុំផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត (Verifier)

នាយកដ្ឋានដោនស្ទ្រីម ដែលពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត មានភារកិច្ចទទួលខុសត្រូវ ដូចខាងក្រោម៖

- ពិនិត្យនិងផ្ទៀងផ្ទាត់ភាពគ្រប់គ្រាន់ និងត្រឹមត្រូវនៃទិន្នន័យដែលបានបំពេញក្នុងប្រអប់ព័ត៌មាននៃប្រព័ន្ធបញ្ជរតែមួយជាតិ និងឯកសារគាំទ្រនានាដែលបានភ្ជាប់ក្នុងទម្រង់អេឡិចត្រូនិក
- ពិនិត្យភាពគ្រប់គ្រាន់និងត្រឹមត្រូវនូវប្រភេទ បរិមាណ ប្រភពនៃប្រេងកាតនិង/ឬផលិតផលប្រេងកាត ដែលជាកម្មវត្ថុនៃការស្នើសុំផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- ស្នើឱ្យអ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត កែតម្រូវបំពេញបន្ថែម និង/ឬផ្តល់ឯកសារគាំទ្រនានាបន្ថែមក្នុងទម្រង់អេឡិចត្រូនិក។ ក្នុងករណីចាំបាច់ អគ្គនាយកដ្ឋានប្រេងកាត អាចអញ្ជើញអ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាតមកធ្វើការបំភ្លឺ ឬផ្តល់ព័ត៌មានដោយផ្ទាល់

- បដិសេធសំណើសុំផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ក្នុងករណីរកឃើញមានភាពមិនត្រឹមត្រូវ មិនអាចកែតម្រូវ ឬបំពេញបន្ថែមបាន និង/ឬមិនស្ថិតក្នុងកម្មវត្ថុនៃការផ្តល់គោលការណ៍ឯកភាពលើផែនការនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាតប្រចាំឆ្នាំ និងលិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត និង
- បោះពុម្ពលិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាតជាឯកសាររឹង (Hard Copy) ក្នុងករណីមានការស្នើសុំរបស់អ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ក្រោយពីមានការសម្រេចពីថ្នាក់ដឹកនាំនៃក្រសួងរ៉ែនិងថាមពល។

### ៤- ការទូទាត់បង់ប្រាក់លើសំណើសុំផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត (Cashier)

ការិយាល័យចរាចរកិច្ចព្រមព្រៀងនិងគ្រប់គ្រងគម្រោងវិនិយោគរបស់នាយកដ្ឋានអភិវឌ្ឍប្រេងកាតនៃអគ្គនាយកដ្ឋានប្រេងកាត ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ពិនិត្យព័ត៌មានក្នុងបណ្ណបង់ប្រាក់ដែលអ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត បានបញ្ចូលក្នុងប្រព័ន្ធ និង
- បំពេញលេខរៀងដើម្បីកំណត់សម្គាល់ក្នុងប្រព័ន្ធ រួចចុចពាក្យ "**បានបង់ប្រាក់រួច**"។

### ៥- ការត្រួតពិនិត្យឡើងវិញលើសំណើសុំផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត (Reviewer)

ថ្នាក់ដឹកនាំដែលជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពល មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

- ត្រួតពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់និងត្រឹមត្រូវនៃសំណើសុំផ្តល់លិខិតអនុញ្ញាតនាំចូលប្រេង-កាតនិង/ឬផលិតផលប្រេងកាត ដែលទទួលបានការឯកភាព និង
- បញ្ជូនត្រឡប់ទៅតាមបេនាសម្ព័ន្ធក្នុងប្រព័ន្ធបញ្ជរតែមួយជាតិដើម្បីពិនិត្យនិងផ្ទៀងផ្ទាត់ ក្នុងករណីរកឃើញមានភាពមិនប្រក្រតី។

### ៦- ការសម្រេចសំណើសុំផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត (Approver)

ថ្នាក់ដឹកនាំនៃក្រសួងរ៉ែនិងថាមពល មានភារកិច្ចទទួលខុសត្រូវ ដូចខាងក្រោម៖

- ពិនិត្យនិងសម្រេចលើការផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត តាមសំណើរបស់អ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត
- បញ្ជូនត្រឡប់ទៅអគ្គនាយកដ្ឋានប្រេងកាត ដើម្បីពិនិត្យនិងផ្ទៀងផ្ទាត់ ក្នុងករណីរកឃើញចំណុចខ្វះខាតដែលត្រូវបំពេញបន្ថែម និង
- បដិសេធសំណើសុំផ្តល់លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត។

**រំហូរ និងថិរវេលានៃនីតិវិធីនៃកិច្ចដំណើរការក្នុងការអនុញ្ញាតឱ្យនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត តាមប្រព័ន្ធបញ្ជរតែមួយជាតិ ជាឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃសេចក្តីណែនាំនេះ។**

ក្រសួងរ៉ែ និង ថាមពល

បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត អ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ត្រូវបញ្ចូលទិន្នន័យលេខលិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត និងទិន្នន័យចាំបាច់ផ្សេងទៀត នាពេលបំពេញប្រតិវេទន៍គយក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មគយ។

ទទួលបានសេចក្តីណែនាំនេះ សូម រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋានជំនាញ មន្ត្រីជំនាញពាក់ព័ន្ធ និងអ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត ត្រូវអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០២៦ នេះតទៅ។

ថ្ងៃពុធ ១២កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៥

ជ. រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

**រដ្ឋលេខាធិការ**

**ស៊ុយ ឌីម៉ង់**

**កន្លែងទទួល៖**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានប្រេងកាត
- នាយកដ្ឋានដោនស្ទ្រីមនិងអង្គភាពពាក់ព័ន្ធ
- អ្នកនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំលេខ ១៣៦៦ [illegible] ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៥**

**ដំណើរនីតិវិធីការងារ នៃការស្នើសុំលិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត តាមប្រព័ន្ធបញ្ជរតែមួយជាតិ**



## ឧបសម្ព័ន្ធទី២ នៃសេចក្ដីណែនាំលេខ ១៣១៧ ឧ.អក.សណរ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៥

## ថិរវេលានៃរំហូរនីតិវិធីនៃកិច្ចដំណើរការចេញលិខិតអនុញ្ញាតឱ្យនាំចូលប្រេងកាតនិង/ឬ ផលិតផលប្រេងកាត តាមប្រព័ន្ធបញ្ជរតែមួយជាតិ

(រយៈពេលនៃថ្ងៃធ្វើការ)

| ល.រ | អ្នកនាំចូល | មន្ត្រីពិនិត្យ | | | | មន្ត្រីបេឡា | ក្រុមហ៊ុន | មន្ត្រីបេឡា | ថ្នាក់ដឹកនាំពិនិត្យឡើងវិញ | | | | ថ្នាក់ដឹកនាំពិនិត្យអនុម័ត | សរុបថិរវេលានៅក្នុងដែនសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | (ពីរថ្ងៃកន្លះ) | | | | (កន្លះថ្ងៃ) | (មិនកំណត់) | (កន្លះថ្ងៃ) | (មួយថ្ងៃ) | | | | (កន្លះថ្ងៃ) | |
| ១ | លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬ ផលិតផលប្រេងកាត | ការិយាល័យជំនាញ | នាយកដ្ឋានជំនាញ | អគ្គនាយករងទទួលបន្ទុក | ប្រព័ន្ធជូនដំណឹងទៅក្រុមហ៊ុនដើម្បីធ្វើការបង់ប្រាក់ | ចេញលិខិតបញ្ជាបង់ប្រាក់ព្រីនចេញពីប្រព័ន្ធ NRMIS | ក្រុមហ៊ុនត្រូវធ្វើការបង់ប្រាក់និងបញ្ចូលបណ្ណបង់ប្រាក់ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ | មន្ត្រីបេឡាត្រូវអនុម័តបញ្ជូនឯកសារបន្ត | អគ្គនាយក | អនុរដ្ឋលេខាធិការ | រដ្ឋលេខាធិការទទួលបន្ទុក | រដ្ឋលេខាធិការទទួលបន្ទុកចង្កោម | រដ្ឋមន្ត្រី | (ប្រាំថ្ងៃ) |

ក្រសួងរ៉ែ និង ថាមពល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ..................................

Date:

# លិខិតអនុញ្ញាតនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត

## PERMISSION LETTER TO IMPORT PETROLEUM AND/OR PETROLEUM PRODUCTS

| | |
|---|---|
| ផ្តល់ជូន (Issued to) : | លេខ អ.ត.ប. (VAT TIN No.): |
| អាសយដ្ឋាន (Address) : | ទូរស័ព្ទ (Phone) : |

យោង៖ - ប្រកាសលេខ១៥៥៥២ រថ.នក.ប្រក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំនាំចូលប្រេងកាតនិង/ឬផលិតផលប្រេងកាត
- អាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់សកម្មភាពនាំចូលលេខ៖.............. ចុះថ្ងៃទី......... ខែ....... ឆ្នាំ.......... របស់ក្រសួងរ៉ែនិងថាមពល
- គោលការណ៍ឯកភាពលើផែនការនាំចូលប្រចាំឆ្នាំលេខ៖.............. ចុះថ្ងៃទី......... ខែ........ ឆ្នាំ.......... របស់ក្រសួងរ៉ែនិងថាមពល
- លិខិតស្នើសុំលេខ៖......... ចុះថ្ងៃទី............ ខែ............ ឆ្នាំ............របស់ក្រុមហ៊ុន..............................................................................

| ល.រ No. | ការពិពណ៌នាពីទំនិញ Goods Description | បរិមាណ (តោន) Quantity (Tone) | ប្រភព/ប្រទេសដើម Source/Country of Origin | ពីក្រុមហ៊ុន From Company | តាមមាត់ច្រក Port of Discharge |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

មានសុពលភាពហូតដល់ (Valid Until): ..........................................................................................................................................

រដ្ឋមន្ត្រី
Minister